# កន្លែងទុកដាក់សម្រាមទប់កណ្ដុរ

គ្រប់គ្រងធនធានម្ហូបអាហារ ជាពិសេសសម្រាម គឺជាវិធីប្រសើរបំផុតក្នុងការគ្រប់គ្រងចំនួនសត្វកណ្ដុរ។ ខាងក្រោមនេះ ជាដំបូន្មានងាយៗសម្រាប់ការទុកដាក់សម្រាម ដើម្បីការពារអាជីវកម្ម និងភូមិដ្ឋានរបស់អ្នក កុំឲ្យមានភ្ញៀវដែលមិនចង់បានទាំងនេះ!

ទុកដាក់កន្លែងចាក់សម្រាម ធុង និងរបស់ទុកដាក់សម្រាមឯទៀតឲ្យបានបិទជិតល្អ**នៅពេលយប់។**



បើអ្នកឃើញរបស់ទុកដាក់សម្រាមរបស់អ្នក ពេញហៀរពេកជាប្រចាំ ចូរគិតគូរកទិញប្រដាប់ដាក់សម្រាមដែលធំជាងនេះ ឬលៃលកឲ្យមានប្រដាប់ដាក់សម្រាមច្រើនជាងនេះ ឬយកសម្រាមទៅបោលឲ្យបានញឹកញាប់។ ត្រូវធ្វើយ៉ាងណាមើលប្រដាប់ដាក់សម្រាមទាំងនេះ កុំឲ្យមានប្រេះ ឬមានធ្លុះធ្លាយ!



ត្រូវធ្វើយ៉ាងណាឲ្យប្រកដថា**បុគ្គលិក** យល់ដឹងអំពីរបៀបប្រើប្រាស់ធុងសម្រាមឲ្យបានត្រឹមត្រូវ។

ពួកគេគួរយល់ដឹងអំពីសារសំខាន់ក្នុងការបិទធុងសម្រាមឲ្យជិតល្អ និងមិនត្រូវដាក់សម្រាមឲ្យហៀរធុង ចងថង់សម្រាមឲ្យជិត លាងសម្អាតអ្វីដែលកំពប់ និងយួរសម្រាមទៅដាក់ធុងសម្រាម ជាជាងអូសវា។

ចូរទុកដាក់សម្រាម **ឲ្យឆ្ងាយពីអ្វីដែលខ្ពស់** ដូចជាជញ្ជាំងរបង បង់អង្គុយ ដើមផ្កា ឬតុ



សត្វកណ្ដុរអាចប្រើប្រាស់ទីដែលខ្ពស់ទាំងនេះ ដើម្បីឡើងទៅរកធុងសម្រាម។ អ្នកអាចយករបង ឬជញ្ជាំងដែលជាប់នឹងដីធ្វើជាកន្លែងបិទជិត ដើម្បីទុកដាក់ធុងសម្រាម ដើម្បីកុំឲ្យសត្វកណ្ដុរចូលបាន។



ចូរទុកដាក់ធុងសម្រាមលើ**បេតុង ឬកន្លែងដែលអ៊ុតកៅស៊ូ**
កុំដាក់ផ្ទាល់លើដី

ធ្វើដូច្នេះនឹងជួយការពារកុំឲ្យកណ្ដុរកាយរូងក្រោមធុងសម្រាមនោះ។

**ប្រើថង់ផ្លាស្ទិកក្រាស់** ដែលអាចចង់ឲ្យជិតល្អ។



ធ្វើដូច្នេះនឹងជួយទប់ក្លិនសម្រាម និងការលេចធ្លាយ ដែលធ្វើឲ្យកណ្ដុរពិបាករកសម្រាមឃើញ។

**ការងាយរកអាហារបាន គឺជាដើមហេតុមួយដ៏ងាយបំផុត សម្រាប់ឲ្យមានសកម្មភាពសត្វកណ្ដុរនៅក្នុងតំបន់ណាមួយ។**

ការលុបបំបាត់ប្រភពអាហារទាំងនេះ គឺជាវិធីងាយស្រួលបំផុត និងមិនអស់ប្រាក់ ក្នុងការបង្ការសត្វចង្រៃទាំងនេះ កុំឲ្យវាក្លាយជាបញ្ហា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅផ្នែកសេវាអភិវឌ្ឍន៍ តាមលេខទូរស័ព្ទនេះ៖
978-674-4144

ដើម្បីរាយការណ៍អំពីវត្តមានសត្វកណ្ដុរ ឬដាននៃសកម្មភាពកណ្ដុរ សូមអ៊ីម៉េលទៅ៖
rodents@lowellma.gov